# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ៖**

## របាយការណ៍ ស្តីពីសកម្មភាពការងារប្រចាំត្រីមាសទី៣ ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

**ស្ថានភាពរួម ៖**

នៅជាងពាក់កណ្តាលឆ្នាំ ២០០៥នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិបានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## I.ការងារដែលអនុវត្តកន្លងមក ៖

**ក.ការងារកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌**

- ប្រជុំក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងតុលាការ (Technical Working Group) ក្រោមអធិបតីភាពឯកឧត្តម **សំ សុខផល** នៅទីស្តីការគណៈរដ្ឋមន្ត្រី
- បោះពុម្ពកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីធ្វើការចែកជូន និងផ្សព្វផ្សាយ
- ប្រជុំផ្ទៃក្នុងដើម្បីជម្រុញឱ្យការងាររបស់ក្រុមគម្រោងមានដំណើរការល្អទៅមុខ និងណែនាំកែសម្រួលអំពីការពិពណ៌នាអំពីគម្រោង (Project Profile)
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារ កាំបូឌីយាណា ជូនក្រសួងស្ថាប័នអ្នកអនុវត្ត
- ប្រជុំជាមួយសង្គមស៊ីវិលផ្សព្វផ្សាយ កម្មវិធីសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌

- ជួបជាមួយក្រសួងយុត្តិធម៌ស្វែងយល់ពីការអនុវត្តយុទ្ធសាស្ត្រកណ្តាប់ដៃដែកក្នុងវិន័យយុត្តិធម៌ និងគម្រោងយុត្តិធម៌ និងគម្រោងយុត្តិធម៌នៅមូលដ្ឋាន
- ប្រជុំផ្ទៃក្នុងត្រួតពិនិត្យឡើងវិញនូវបញ្ជីគម្រោងដោយផ្តោតទៅលើលទ្ធផលរំពឹងទុក
- ប្រជុំជាមួយប្រទេសផ្តល់ជំនួយ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **ស៊ុំ ម៉ានិត** ដើម្បីបង្ហាញពីផែនការសកម្មភាពសម្រាប់អនុវត្តន៍កំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥
- ប្រជុំរៀនសូត្រ អំពីការវាយតម្លៃចំណាយទៅលើគម្រោង
- ជួបពិភាក្សាជាមួយគណៈប្រតិភូក្រសួងការបរទេសដាណឺមាកដឹកនាំដោយលោកស្រី Darriann Riber ដើម្បីស្វែងយល់ដកពិសោធន៍លើសហប្រត្តិបត្តិការ រវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍-អង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ និងវិទ្យាស្ថានដាណឺមាកសម្រាប់សិទ្ធិមនុស្សកន្លងមក
- ជួបជាមួយ EWMI លើគម្រោងសិក្សាស្រាវជ្រាវ អំពីជំនួយផ្នែកច្បាប់
- ផ្ញើជូនក្រសួងពាក់ពន្ធ័នូវឯកសារស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ
- កិច្ចប្រជុំពិភាក្សាតុមូលស្តីពីកំណែទម្រង់ និងការប្រមើលមើលប្រពន្ធ័យុត្តិធម៌នៅកម្ពុជា នៅសណ្ឋាគារ Sunway ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ។
- ចូលរួមប្រជុំនៅក្រុមប្រឹក្សាអ្នកច្បាប់ ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី ០១-០៩-២០០៥
- ចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ក្រោមអធិបតីភាពឯកឧត្តម **សំ សុខផល** ថ្ងៃទី ០៥-០៩-២០០៥
- ចូលរួមប្រជុំបន្ត នៅក្រុមប្រឹក្សាអ្នកច្បាប់ ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី ០៨-០៩-២០០៥
- ប្រជុំផ្ទៃក្នុងដើម្បីជម្រុញឱ្យការងាររបស់ក្រុមគម្រោងមានដំណើរការល្អទៅមុខ និងពិភាក្សាលើ (Project Catalogue, formal Work Plan ) ថ្ងៃទី ១៦-០៩-២០០៥ ។

**ខ.ការចារទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ**

- ចូលរួមប្រជុំអន្តរក្រសួង
- ចូលរួមសិក្ខាសាលាអន្តរជាតិស្តីពីការធ្វើច្បាប់ប្រឆាំងនឹងអំពើពុករលួយ នៅមហាវិទ្យាល័យបញ្ញាសាស្ត្រចំនួនពីរ លើក គឺនៅថ្ងៃទី ១៤-១៥ ខែកក្កដា ឆ្នាំ ២០០៥ កន្លងទៅថ្មីៗនេះ
- បានចូលរួមសិក្ខាសាលាអំពីសេរីភាពទទួលបានសារព័ត៌មាន
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រោមអធិបតីភាព ឯកឧត្តម **ឆាយ ថន** នៅសណ្ឋាគារ Inter-continental ចំនួនពីរលើក កាលពីថ្ងៃទី ២៧-២៨ ខែ កក្កដា ឆ្នាំ ២០០៥ ។
- ចូលរួមប្រជុំជាមួយស្ថានទូតបារាំង និងក្រសួងយុត្តិធម៌ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ី សោភា** អំពីការងារទាក់ទងនឹងពាក្យបច្ចេកទេសក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបញ្ហាធ្វើច្បាប់ស្តីពីអង្គការចាត់តាំងតុលាការ
- ជួបប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់អំពីក្រមនីតិវិធីព្រហ្មទណ្ឌ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល**

- ជួបជាមួយតំណាងខាង AusAid អំពី Logical Framework Approach
- ជួបជាមួយតំណាង UNDP ក្រោមប្រធានបទ ច្បាប់ប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល**
- ជួបប្រជុំជាមួយគណៈប្រតិភូបារាំង ដឹកនាំដោយលោក Patrice Davost នាយកសេវាកម្មយុត្តិធម៌ នៃ ក្រសួងយុត្តិធម៌
- ប្រជុំបន្តជាមួយតំណាងខាង AusAid អំពីការវិភាគយុទ្ធសាស្ត្រ
- បន្តការជួបជាមួយប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់អំពីក្រមនីតិវិធីព្រហ្មទណ្ឌ
- ចូលរួមសិក្ខាសាលាស្តីពីនីតិវិធីជំនុំជម្រះក្តីព្រហ្មទណ្ឌ នៅសណ្ឋាគារសាន់វេ
- ចូលរួមវេទិកាតុមូលនៃក្លឹបអ្នកកាសែតកម្ពុជា ស្តីពីកំណែទម្រង់ច្បាប់ និងតុលាការ ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមប្រជុំអន្តរក្រសួង ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ កាលពីថ្ងៃទី១៣-០៩-២០០៥
- ចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសនៅ CDC ស្តីពីការកំណែទម្រង់រដ្ឋក្រោមអធិបតីភាព ឯកឧត្តម **គាត ឈន់** ថ្ងៃទី ១៥-០៩-២០០៥
- ប្រជុំបន្តជាមួយអន្តរក្រសួង ស្តីពីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ កាលពីថ្ងៃទី ២១-០៩-២០០៥
- ចូលរួមប្រជុំស្តីពីអភិបាលកិច្ចល្អលើ Gap II ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២១-០៩-២០០៥
- ចូលរួមប្រជុំជាមួយសង្គមស៊ីវិល ស្តីពីសេរីភាពទទួលបានព័ត៌មាន ថ្ងៃទី ២២-០៩-២០០៥។
-

**ឥ.ការងារសហប្រតិបត្តិការអន្តរជាតិ**

- ចុះស្វែងយល់ជាមួយគណៈប្រតិភូវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស (DIHR) អំពីរដ្ឋបាលតុលាការនៅក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍ និងតុលាការកំពូល
- ជួបជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដើម្បីពិភាក្សាលើបញ្ហាពុករលួយ និងលើសេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង វិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស (DIHR) និងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) បន្តសម្រាប់ឆ្នាំ២០០៥
- ពិនិត្យរៀបចំរបាយការណ៍ស្តីពីការសិក្សាស្វែងយល់អំពីយន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ រៀបចំដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)
- ជួបជាមួយអគ្គរាជទូតដាណឺម៉ាក ស្តីពីកម្មវិធីចុះសិក្សាបញ្ហាយុត្តិធម៌នៅកម្ពុជា
- ចូលរួមសិក្ខាសាលានៅកាំបូឌីយ៉ាណា ស្តីពីកម្មវិធីសម្រាប់យុត្តិធម៌ នៅតំបន់អាស៊ី ប៉ាស៊ីហ្វិច ដែលរៀបចំដោយ UNDP

## II. សេចក្តីសន្និដ្ឋាន

នៅក្នុងត្រីមាសទី២ ឆ្នាំ២០០៥នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានបំពេញការងារយ៉ាងសកម្ម ហើយសម្រេចបាននូវលទ្ធផលដ៏ប្រសើរ

សម្រាប់ការអនុវត្តនូវកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ គឺបានរៀបចំរួចរាល់ជាស្រេចនូវឯកសារកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច និងត្រៀមនូវលក្ខណៈសម្បត្តិចាំបាច់មួយចំនួន ដើម្បីអនុវត្តជាបន្តបន្ទាប់ពីការអនុម័តកម្មវិធីសកម្មភាពនេះ ។

## III. ទិសដៅសម្រាប់អនុវត្តបន្ត

- បញ្ចប់ការរៀបចំបញ្ជីគម្រោង និងផែនការការងារសម្រាប់ការគ្រប់គ្រងគម្រោងទាំងមូល
- រៀបចំសិក្ខាសាលាធ្វើការផ្សព្វផ្សាយកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ
- ស្វែងរកអ្នកឧបត្ថម្ភសម្រាប់សកម្មភាពអាទិភាពរយៈពេលខ្លីដែលពុំទាន់ចាប់ផ្តើមចំនួន៨សកម្មភាព
- តាមដានការអនុវត្តសកម្មភាពអាទិភាពដែលកំពុងតែដំណើរការ
- ស្វែងយល់ពីការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះរវាងតំណាងរាជរដ្ឋាភិបាល និងតំណាងសហគមន៍ផ្តល់ជំនួយអំពីកិច្ចសហប្រតិបត្តិការខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបំពេញកាតព្វកិច្ចតាមសូចនាករតាមដានរួម ដែលបានកំណត់ ដោយកិច្ចប្រជុំពិគ្រោះយោបល់កាលពីថ្ងៃទី ០៦-០៧ ខែធ្នូ ឆ្នាំ២០០៤ ខិតខំអនុវត្តសកម្មភាពជាអាទិភាពដែលបានកំណត់ក្នុងឯកសារកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ។
- បន្តពង្រឹងសមត្ថភាពរបស់អង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីសកម្មភាពនៃកំណែទម្រង់មានដំណើររលូន និងពេញលេញដូចដែលបានគ្រោងទុក ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៥*

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

ប្រធាន អ.គ.គ

សេង វ៉ាន់ដា

**ស៊ុយ ម៉ុងលាង**